ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់គោលការណ៍វិនិយោគលើធនធានរ៉ែគ្រប់ប្រភេទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១
- យោងសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១:** រាល់សំណើសុំសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មលើធនធានរ៉ែ ត្រូវឆ្លងកាត់ "ច្រកចេញ-ចូលតែមួយ" នៃក.អ.ក បន្ទាប់ពីមានការផ្តល់យោបល់ពីស្ថាប័នសាមីរួចហើយ ។

**<u>មាត្រា២</u>:** ធនធានរ៉ែធម្មជាតិគ្រប់ប្រភេទ មិនត្រូវបានអនុញ្ញាតអោយនាំចេញឡើយ ដោយត្រូវរក្សាធនធានរ៉ែទាំងនោះ សំរាប់ផ្គត់ផ្គង់សេចក្តីត្រូវការរបស់រោងចក្រក្នុងស្រុក ដើម្បីកែច្នៃជាផលិតផលសំរេច ។ មានតែផលិតផលសំរេចប៉ុណ្ណោះ ដែលអាចអនុញ្ញាតអោយនាំចេញទៅក្រៅប្រទេសបាន ។

**<u>មាត្រា៣</u>:** រាល់ការសំរេចទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនេះ នឹងចាត់ទុកជានិរាករណ៍ ។

**<u>មាត្រា៤</u>:** សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី- សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីគ្រប់ក្រសួង-គ្រប់អភិបាលខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥.

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
អនុប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា

**ចម ប្រសិទ្ធ**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រុមព្រះ
- ដូចមាត្រា៤ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ